# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ១៣០/០៧ គ.ជ.ប**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ជំរាបមក**

**លោក ហេរ្ស៊ម ជៀង នាយកវិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ (NDI)**

**កម្មវត្ថុ :** ករណីចាក់ផ្សាយវេទិការពិភាក្សាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅស្ថានីយ៍វិទ្យុជាតិ

**យោង :** - លិខិតរបស់លោក **ហេរ្ស៊ម ជៀង** នាយកវិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០០៧

- គោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្សនយោបាយក្នុងអំឡុងពេលបោះឆ្នោត

តាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជម្រាបជូនលោកនាយកវិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យជ្រាបថា គ.ជ.ប បានចេញ គោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំនួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

ចំពោះសំណើរបស់វិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ លើការចាក់ផ្សាយវេទិការពិភាក្សាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅស្ថានីយ៍វិទ្យុជាតិ គ.ជ.ប មិនជំទាស់ទេ ប៉ុន្តែសូមលោកនាយកត្រូវអនុវត្តតាមគោលការណ៍របស់ គ.ជ.ប ដូចបានជម្រាបជូនខាងលើ ។ ជាពិសេស **ការផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយតាមវិទ្យុ ឬទូរទស្សន៍ ត្រូវមានការចូលរួមគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជាផ្លូវការទាំងអស់ក្នុងខេត្តក្រុងណាមួយ ឬទូទាំងប្រទេស ទើបអាចផ្សព្វផ្សាយបាន ។**

គ.ជ.ប សង្ឃឹមថា ការចូលរួមចំណែកក្នុងការងារបោះឆ្នោតរបស់ វិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យពិតជាជួយជំរុញឱ្យការងារបោះឆ្នោតឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧ នេះ ទទួលបានលទ្ធផលល្អ ។

សូមលោកនាយកទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

**គ.ប គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

**ទេព នីថា**